# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**លេខ** ០៤១១/១៦ អ គ រ

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦

**ជម្រាបមក**

**លោក លោកស្រី ប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ**

**កម្មវត្ថុ**: ការដាក់ឱ្យអនុវត្តមុខងារគ្រប់គ្រងទំនិញមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធនិងអាករ តាមបទប្បញ្ញត្តិច្បាប់ជាធរមានពេលនាំចេញ-នាំចូល តាមមធ្យោបាយអេឡិកត្រូនិក ។

**យោង**:
- សេចក្តីណែនាំលេខ ១៣០៨ អគរ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីនីតិវិធីលំអិត និងភារកិច្ចទទួលខុសត្រូវក្នុងកិច្ចដំណើរការប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ) តាមមធ្យោបាយអេឡិកត្រូនិក
- សេចក្តីណែនាំលេខ ៨៩៦/៩៦ គ.រ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៦ ស្តីពីការចុះបញ្ជិកាគណនេយ្យ ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបមកលោក លោកស្រីជ្រាបថា ដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀតនូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការប្រមូលចំណូលពន្ធនិងអាករ ក៏ដូចជាស្ថិតិទំនិញនាំចេញ-នាំចូល អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) សម្រេចដាក់ឱ្យដំណើរការមុខងារប្រព័ន្ធគ្រប់គ្រងទំនិញមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធនិងអាករ តាមបទប្បញ្ញត្តិច្បាប់ជាធរមានពេលនាំចេញ-នាំចូល ។ ប្រព័ន្ធនេះ ជាផ្នែកមួយនៃប្រព័ន្ធអេឡិកត្រូនិកគយ (e-Customs) និងមានមុខងារសំខាន់ៗជាអាទិ៍ ការកត់ត្រាទំនិញស្ម័គ្រចិត្តបំពេញកាតព្វកិច្ចពន្ធនិងអាករ ទំនិញល្មើស ការបង្កើតនិងបោះពុម្ពបង្កាន់ដៃពន្ធគយ បង្កាន់ដៃបង់ប្រាក់ បង្កាន់ដៃពន្ធយានយន្ត ដោយបំពាក់នូវឃ្យូអារកូដ (QR Code) ដូចមានចែងក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រី ចាត់ចែងអនុវត្តតាមខ្លឹមសារនៃលិខិតនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ នេះតទៅ ។

សូមលោក លោកស្រី ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំ ។

**អគ្គនាយក**
**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**បណ្ឌិត គុណ–ញឹម**

**ជូនភ្ជាប់**÷
- គំរូបង្កាន់ដៃពន្ធគយ "ឧបសម្ព័ន្ធ ១"
- គំរូបង្កាន់ដៃបង់ប្រាក់ "ឧបសម្ព័ន្ធ ២"
- គំរូបង្កាន់ដៃពន្ធយានយន្ត "ឧបសម្ព័ន្ធ ៣"

**ចម្លងជូន**÷
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
  "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"
- ឯកសារ - កាលប្បវត្តិ

អាសយដ្ឋានៈ លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារៈ (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

# ឧបសម្ព័ន្ធ ១ ÷ គំរូបង្កាន់ដៃពន្ធគយ

(នៃលិខិតលេខ ១២១១/១៦ អ.គ.រ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្ដីពីការដាក់ឲ្យអនុវត្តមុខងារគ្រប់គ្រងទំនិញមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធនិងអាករតាមបទប្បញ្ញត្តិច្បាប់ជាធរមានពេលនាំចេញ-នាំចូល តាមមធ្យោបាយអេឡិកត្រូនិក)

ព្រះរាជាណាចក្រកម្ពុជា

**Kingdom of Cambodia**

ជាតិ សាសនា ព្រះមហាក្សត្រ

**Nation Religion King**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**General Department of Customs and Excise**

លេខ និងកាលបរិច្ឆេទ No. & Date

2016 P-2 08/07/2016

## បង្កាន់ដៃពន្ធគយ
## CUSTOMS RECEIPT

នាយកដ្ឋាន/ សាខា/ ការិយាល័យ Department/Branch/Office: BAT10 - Bat Dambang CEB

បានទទួលពីលោក លោកស្រី Received From: KONG TOLA

អាសយដ្ឋាន Address: THNAL VILLAGE, KRANGLOVEA COMMUNE, SAMKIMEANCHEY DISTRICT, KAMPONG CHHNANG

ក្រុមហ៊ុន Company: 100080413 Sok Sokha Co., Ltd.

| បញ្ជិកាទំនិញ Goods Registration | | យោង Reference | | ទឹកប្រាក់ Amount |
|---|---|---|---|---|
| ឆ្នាំ Year | លេខ Nº | លេខ Nº | កាលបរិច្ឆេទ Date | |
| 2016 | D 2 | 1955/16 | 08/07/2016 | 15,797,000 |
| | | GDCE 469/16 | 08/07/2016 | |
| | | | សរុបចំណូល Total Amount | 15,797,000 |

| កម្រៃផ្សេងៗ Other Fees | | យោង Reference | ទឹកប្រាក់ Amount |
|---|---|---|---|
| PIM | Penalty on Import | GDCE 469/16 dated 08-JUL-2016 | 15,797,000 |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | សរុបចំណូលកម្រៃផ្សេងៗ Total Other Fees | 15,797,000 |

| មធ្យោបាយទូទាត់ Means of Payment | | យោង Reference | ធនាគារ Bank | ទឹកប្រាក់ Amount |
|---|---|---|---|---|
| 10 | In cash | | | 31,594,000 |
| | | | | |
| | | | | |
| | | | សរុបចំណូលពន្ធ និងកម្រៃ Grand Total | 31,594,000 |

សរុបចំណូលពន្ធ និងកម្រៃជាអក្សរ Amount paid in words:

Thirty-one million five hundred and ninety-four thousand Riels

បេឡាករ Cashier :

MOEUN SOPHEAKDEY

## ឧបសម្ព័ន្ធ ២ ÷ គំរូបង្កាន់ដៃបង់ប្រាក់

(នៃលិខិតលេខ ១២១១/១៦ អ.គ.រ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការដាក់ឲ្យអនុវត្តមុខងារគ្រប់គ្រងទំនិញមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធនិងអាករតាមបទប្បញ្ញត្តិច្បាប់ជាធរមានពេលនាំចេញ-នាំចូល តាមមធ្យោបាយអេឡិកត្រូនិក)

**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation Religion King**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
General Department of Customs and Excise

លេខ និងកាលបរិច្ឆេទ No. & Date
2016 O-1 08/07/2016

### បង្កាន់ដៃបង់ប្រាក់
### OTHER PAYMENT RECEIPT

នាយកដ្ឋាន/ សាខា/ ការិយាល័យ Department/Branch/Office: BAT10 - Bat Dambang CEB

បានទទួលពីលោក លោកស្រី Received From: SEN SOKSAN

អាសយដ្ឋាន Address: THNAL VILLAGE, KRANGLOVEA COMMUNE, SAMKIMEANCHEY DISTRICT, KAMPONG CHHNANG

ក្រុមហ៊ុន Company: 999999999 Occasional Company

| កម្រៃផ្សេងៗ Other Fees | | យោង Reference | ទឹកប្រាក់ Amount |
|---|---|---|---|
| TRF | Transit Fee | PRAKAS 1151 MEF dated 15-SEP-2015 | 1,200,000 |
| | | | |
| | | | |
| | | | |
| | | | |
| | | សរុបកម្រៃផ្សេងៗ Total Fees | 1,200,000 |

| មធ្យោបាយទូទាត់ Means of Payment | | យោង Reference | ធនាគារ Bank | ទឹកប្រាក់ Amount |
|---|---|---|---|---|
| 10 | In cash | | | 1,200,000 |
| | | | | |
| | | | សរុបកម្រៃបានបង់ Total Amount Paid: | 1,200,000 |

សរុបកម្រៃបានបង់ជាអក្សរ Total Amount Paid in Words:

One million two hundred thousand Riels

បេឡាករ Cashier

MOEUN SOPHEAKDEY

គំរូបង្កាន់ដៃបង់ប្រាក់

## ឧបសម្ព័ន្ធ ៣ ÷ គំរូបង្កាន់ដៃពន្ធយានយន្ត

(នៃលិខិតលេខ ១២១១/១៦ អ.គ.រ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការដាក់ឲ្យអនុវត្តមុខងារគ្រប់គ្រងទំនិញមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធនិងអាករតាមបទប្បញ្ញត្តិច្បាប់ជាធរមានពេលនាំចេញ- នាំចូល តាមមធ្យោបាយអេឡិកត្រូនិក)

# ព្រះរាជាណាចក្រកម្ពុជា
# Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

**Nation Religion King**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
**General Department of Customs and Excise**

លេខ និងកាលបរិច្ឆេទ No. & Date
2016 V 2 08/07/2016

## បង្កាន់ដៃពន្ធយានយន្ត
## VEHICLE DOCUMENT

Original Copy

នាយកដ្ឋាន/ សាខា/ ការិយាល័យ Department/Branch/Office: BAT10 - Bat Dambang CEB

បញ្ជិកាទំនិញ Goods Registration: 2016 D 2 កាលបរិច្ឆេទ Date: 08/07/2016

ម្ចាស់ទំនិញ ឬអ្នកតំណាង Owner/Representative: KONG TOLA

ក្រុមហ៊ុន Company: 100080413 - Sok Sokha Co., Ltd. អត្រាប្តូរប្រាក់ Exchange Rate: 4,090 KHR

បរិយាយមុខទំនិញ Item Description: USED TOYOTA CAMRY 2009 LEFT 2400CC

| តម្លៃឯកតា Unit Price | កូដប្រភេទពន្ធ Tax Code | មូលដ្ឋានគិតពន្ធ Tax Base | អត្រា Rate | ប្រាក់ពន្ធ Amount | ប.ខ.ទ MP |
|---|---|---|---|---|---|
| 5,000 | COP | 20,450,000 | 15 | 3,067,500 | 1 |
| | SOP | 23,517,500 | 40 | 9,407,000 | 1 |
| | VOP | 32,924,500 | 10 | 3,292,500 | 1 |
| | VVF | 30,000 | 1 | 30,000 | 1 |
| | | | | | |
| | | | | | |
| | | | | | |
| | | | សរុប | 15,797,000 | 1 |

សរុបប្រាក់ពន្ធជាអក្សរ Amount Paid in Words:
Fifteen million seven hundred and ninety-seven thousand Riels

លេខតួ Chassis No: 4T1BE32K62U049916

លេខម៉ាស៊ីន Engine No: 2AZ7063689

លេខវិញ្ញាបនបត្រ Vignette No: 00-113253

កំណត់សម្គាល់÷ បង្កាន់ដៃនេះសម្រាប់យានយន្តមានស្រាប់ក្នុងប្រទេស ។

ប្រធានគណនេយ្យ
**Chief Accountant**

MOEUN SOPHEAKDEY